**សុន្ទរកថា**
**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ហោ ណាំហុង**
**តំណាងដ៏ខ្ពង់ខ្ពស់របស់សម្តេចតេជោនាយករដ្ឋមន្ត្រី**
**ថ្លែងក្នុងឱកាសប្រារព្ធពិធី**
**«ឆ្នាំវប្បធម៌-ទេសចរណ៍ រវាងកម្ពុជានិងចិន»**
**ថ្ងៃទី29 ខែមករា ឆ្នាំ2019**

–ឯកឧត្តម ឡូ ស៊ូកាង រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងទេសចរណ៍ នៃសាធារណរដ្ឋប្រជាមានិតចិន
–ឯកឧត្តម ថោង ខុន រដ្ឋមន្ត្រីក្រសួងទេសចរណ៍
–ឯកឧត្តម លោកជំទាវ លោកឧកញ៉ា លោក លោកស្រី

តាងនាម **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ខ្ញុំមានសេចក្តីសោមនស្សរីករាយក្រៃលែង ដែលបានចូលរួមក្នុងពិធីសម្ពោធទិវា"ឆ្នាំវប្បធម៌-ទេសចរណ៍ កម្ពុជា-ចិន" ដែលជាកម្មវិធីដ៏អធិកអធម រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាមានិតចិន ក្នុងវិស័យវប្បធម៌ និងទេសចរណ៍។

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមស្វាគមន៍ យ៉ាងកក់ក្តៅនិងអរគុណចំពោះ **ឯកឧត្តម ឡូ ស៊ូកាង(Luo Shugang)** រដ្ឋមន្ត្រី ក្រសួងវប្បធម៌និង ទេសចរណ៍ នៃសាធារណរដ្ឋប្រជាមានិតចិន ដែលបានចូលរួមសហការរៀបចំទិវា«ឆ្នាំវប្បធម៌-ទេសចរណ៍ កម្ពុជា-ចិន» ដ៏វិសេសវិសាលនេះ នៅលើទឹកដី នៃព្រះរាជាណាចក្រកម្ពុជានៅថ្ងៃស្អែកនេះ។

នៅឆ្នាំ2018កន្លងទៅ កម្ពុជានិងចិន បានប្រារព្ធពិធីអបអរសាទរ ខួបអនុស្សាវរីយ៍ លើកទី60នៃការបង្កើតទំនាក់ទំនងការទូត រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាមានិតចិន ដែលមានសកម្មភាព វប្បធម៌ និងសកម្មភាពផ្សេងៗទៀតជាច្រើន ដើម្បីអបអរសាទរខួបអនុស្សាវរីយ៍នេះ។

ក្នុងរយៈពេល60ឆ្នាំនេះ ប្រទេសយើងទាំងពីរ បានជួយគាំទ្រគ្នាទៅវិញទៅមកលើគ្រប់រូបភាព ដើម្បីរក្សាសន្តិភាព ការអភិវឌ្ឍ និងការរីកចំរើនលើគ្រប់វិស័យ ដែលមានផលប្រយោជន៍ ដ៏ធំធេងសម្រាប់ប្រជាជននៃប្រទេសយើងទាំងពីរ ក៏ដូចជាការរួមចំណែកកសាងសន្តិភាព និងវឌ្ឍនភាពក្នុងតំបន់។

កន្លងមកកម្ពុជានិងចិន បានធ្វើការផ្លាស់ប្តូរគណៈប្រតិភូថ្នាក់ដឹកនាំកំពូល និងថ្នាក់ដឹកនាំផ្សេងទៀតជាច្រើន ដើម្បីពង្រីកពង្រឹងមិត្តភាពដ៏យូរលង់ជាប្រពៃណី និងកិច្ចសហប្រតិបត្តិការ ដែលមានផលប្រយោជន៍ យ៉ាងច្រើនដល់ប្រជាជន និង ប្រទេសយើងទាំងពីរ។

ទស្សនៈកិច្ចផ្លូវការរបស់**សម្តេចអគ្គ មហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ប៉ុន្មានថ្ងៃមុននេះនៅប្រទេសចិនបាន ទទួលលទ្ធផលដ៏ធំធេង ក្នុងការពង្រីកពង្រឹង មិត្តភាពយ៉ាងកក់ក្តៅ និងកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធ និងមានផ្លែផ្កា រវាង ប្រទេសយើង

*ទាំងពីរ។ ហើយ "ឆ្នាំវប្បធម៌-ទេសចរណ៍ កម្ពុជា-ចិន" ឆ្នាំ2019នេះ ក៏ជាលទ្ធផលនៃការឯកភាព រវាង សម្ដេចអគ្គមហាសេនាបតីតេជោ និង ឯកឧត្តម លី ខឺឈាង នាយករដ្ឋមន្ត្រី នៃសាធារណរដ្ឋប្រជាមានិត ចិនដែរ។*

*ក្នុងឱកាសទស្សនៈកិច្ចនេះដែរ ឯកឧត្តម Xi Jinping ប្រធានាធិបតី នៃសាធារណរដ្ឋ ប្រជាមានិត ចិន បានប្រកាសផ្ដល់ជំនួយដល់កម្ពុជាចំនួន4.000លានយាន់ និងទិញអង្ករពីកម្ពុជាចំនួន400.000តោន ក្នុងឆ្នាំ2019នេះ។ រួមទាំងការប្ដេជ្ញាការពារ បដិវត្តន៍ពណ៌ និងការការពារ សុខសន្តិភាព ក្នុងតំបន់។*

- *ឯកឧត្តម លោកជំទាវ លោក លោកស្រី*

*វិស័យទេសចរណ៍កម្ពុជា មានសក្ដានុពលធំធេងណាស់ ដែលមានប្រាសាទជាង1000 សក្តិសម នឹងកិត្តិនាម**ជា«ព្រះរាជាណាចក្រអច្ឆរិយៈ»** រួមទាំងសម្បត្តិវប្បធម៌អូបីយ និងតំបន់អេកូ-ទេសចរណ៍ សំបូរបែប។*

*រដ្ឋាភិបាលចិនក៏បានរួមចំណែកយ៉ាងធំធេង ជួយជួសជុលប្រាសាទក្នុងតំបន់រមណីយដ្ឋានអង្គរ ជាអាទិ៍ជួសជុលប្រាសាទចៅសាយទេវតា និងប្រាសាទតាកែវ នឹងបន្តជួយជួសជុលប្រាសាទបុរាណផ្សេងៗ ទៀត ជាពិសេសប្រាសាទព្រះវិហារ។ សម្បត្តិវប្បធម៌ទាំងអស់នេះរបស់កម្ពុជា ជាប្រភពកាត់មិនដាច់ពីការ រីកចម្រើនអត់ឈប់ឈរនៃទេសចរណ៍កម្ពុជា។*

*ជាក់ស្ដែងកាលពីឆ្នាំ2018កន្លងមក យើងទទួលបានទេសចរអន្តរជាតិប្រមាណ**6.2លាននាក់** ដែលក្នុងនោះទេសចរចិនប្រមាណ**1.9 លាននាក់** ស្ថិតក្នុងលំដាប់លេខ1 ទាំងក្នុង**ឆ្នាំ2017 និងឆ្នាំ2018**។*

*កម្ពុជាសង្ឃឹមថា នឹងទទួលបានទេសចរចិនប្រមាណ **3លាននាក់ នៅឆ្នាំ2020** ហើយនឹងកើនដល់ **5លាននាក់** នៅឆ្នាំ 2025 និងប្រមាណ **8លាននាក់នៅឆ្នាំ 2030**។*

*ការកើនឡើងនៃទេសចរចិនមកទស្សនា កម្ពុជាពីមួយឆ្នាំទៅមួយឆ្នាំ ក៏ដោយសារមានការហោះ ហើរត្រង់ពីចិនមកកម្ពុជា ដោយក្រុមហ៊ុន អាកាសចរចិនចំនួន12 ដែលក្នុងមួយអាទិត្យមានការហោះហើរ មកកម្ពុជាចំនួន207ជើង សរុបក្នុងមួយឆ្នាំមាន1504ជើង ព្រមទាំងថ្មីៗនេះមានការ ហោះហើរត្រង់ ពីប៉េកាំង មកភ្នំពេញផងដែរ។*

*ខ្ញុំមានការជឿជាក់ថា នឹងមានការកើនឡើង នៃការហោះហើរច្រើនថែមទៀត រវាងកម្ពុជានិងចិន ដែលនឹងនាំអោយមាន ទេសចរណ៍ចិនមក ទស្សនាកម្ពុជាកាន់តែច្រើនថែមទៀត។*

*វិស័យទេសចរណ៍នៅកម្ពុជា មិនគ្រាន់តែបានរួមចំណែកយ៉ាងសំខាន់ នៃចំណូលថវិកាជាតិតែ ប៉ុណ្ណោះទេ តែក៏ជាកត្តាមួយយ៉ាងសំខាន់ ក្នុងការកាត់បន្ថយភាពក្រីក្រ ដែលសព្វថ្ងៃមានតែត្រឹមរង្វង់ 10%។ ទេសចរណ៍ក៏បានរួមចំណែកប្រមាណ12,7% នៃផលិតផលក្នុងស្រុកសរុប(GDP) និងផ្ដល់ការ ងារយ៉ាងច្រើនដោយផ្ទាល់ និង ដោយប្រយោលដល់ប្រជាជនកម្ពុជាដែរ។*

*ការកើនឡើងនៃទេសចរចិនក៏ដូចជាទេសចរអន្តរជាតិក៏ជាផ្នែកមួយយ៉ាងសំខាន់ នៃការអភិវឌ្ឍន៍ យ៉ាងធំធេងរបស់កម្ពុជា លើគ្រប់វិស័យ ដោយសារកម្ពុជាមានសន្តិភាព ពេញលេញបានមក ពីនយោបាយ ឈ្នះ-ឈ្នះ របស់**សម្ដេចអគ្គមហាសេនាបតីតេជោ** កាលពី20ឆ្នាំមុន។*

ដោយសារសន្តិភាពនេះហើយបានជា ក្នុងរយៈពេលជាច្រើនឆ្នាំកន្លងមកកម្ពុជា សម្រេចបានកំណើនសេដ្ឋកិច្ចក្នុងរង្វង់7% ក្នុងមួយឆ្នាំ ហើយក្នុងឆ្នាំ2018កន្លងមក កំណើនសេដ្ឋកិច្ចមាន7.3% ដែលធ្វើឲ្យ កម្ពុជាស្ថិតក្នុងចំណោមប្រទេសដែលមានកំណើនសេដ្ឋកិច្ចខ្ពស់ជាងគេ ហើយនឹង ក្លាយជាប្រទេសដែលមានប្រាក់ចំណូល មធ្យមកម្រិតខ្ពស់នៅឆ្នាំ2030 ខាងមុខ។សព្វថ្ងៃកម្ពុជាជាប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតទាប ដែលប្រជាជនម្នាក់ៗ មានប្រាក់ចំណូលក្នុងឆ្នាំ2018 ចំនួន 1563US$។

- ឯកឧត្តម លោកជំទាវ លោក លោកស្រី

ខ្ញុំសូមរំលឹកថា ទំនាក់ទំនងកិច្ចសហប្រតិបត្តិការប្រពៃណីកម្ពុជា-ចិន បានលើកជា«ភាពជាដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយ»តាំងពីឆ្នាំ2010មក ដែលធ្វើអោយទំនាក់ទំនងរវាងប្រទេសយើង ទាំងពីរលើគ្រប់វិស័យកាន់តែស៊ីជម្រៅ។ «ខ្សែក្រវាត់ និងផ្លូវ» ដែលជាគំនិតផ្តួចផ្តើមដ៏សំខាន់បំផុតរបស់ ឯកឧត្តម Xi Jinping ប្រធានាធិបតី នៃសាធារណរដ្ឋប្រជាមានិតចិន បានដើរតួនាទីជាកត្តាសំខាន់ណាស់ ក្នុងការអភិវឌ្ឍន៍កម្ពុជា ពិសេសហេដ្ឋារចនាសម្ព័ន្ធ ស្ពាននិងផ្លូវ។ ការកសាងព្រលានយន្តហោះថ្មីនៅខេត្តសៀមរាប និងផ្លូវល្បឿនលឿន ភ្នំពេញ-ក្រុងព្រះសីហនុ ក៏ជាលទ្ធផលនៃ«ខ្សែក្រវាត់និងផ្លូវ»នេះដែរ ព្រមទាំង សមិទ្ធិផលផ្សេងទៀតជាច្រើន។

ព្រលានយន្តហោះថ្មីនៅខេត្តសៀមរាប និងផ្លូវល្បឿនលឿន ភ្នំពេញ-ក្រុងព្រះសីហនុ ក៏នឹងនាំឲ្យប៉ូលទេសចរណ៍ទាំងពីរនេះ កាន់តែទទួលបានទេសចរចិន និងអន្តរជាតិ កាន់តែច្រើនថែមទៀត។

ការដែលប្រទេសទាំងពីរ បានសម្រេចយកឆ្នាំ2019នេះ ជា**«ឆ្នាំនៃការផ្លាស់ប្តូរ វប្បធម៌ និងទេសចរណ៍»** រវាងប្រទេសយើងទាំងពីរ ក៏ស្ថិតក្នុងក្របខណ្ឌដ៏ថ្លៃថ្លា នៃ«ខ្សែក្រវាត់និងផ្លូវ»ដែរ ធ្វើឲ្យប្រជាជនយើងកាន់តែស្គាល់គ្នា កាន់តែជឿទុកចិត្តគ្នា និងកាន់តែស្រលាញ់រាប់អានគ្នា។ហើយនៅចុងខែមេសា ខាងមុខនេះ **សម្តេចអគ្គមហាសេនាបតីតេជោ** នឹងអញ្ជើញទៅចូលរួមកិច្ចប្រជុំកំពូល«ខ្សែក្រវាត់ និង ផ្លូវ» នៅទីក្រុងប៉េកាំងដែរ ដែលជាកិច្ចប្រជុំកំពូលមួយមានសារសំខាន់ជាសារវន្ត សម្រាប់ប្រទេសជាច្រើន នៅអាស៊ី អ៊ឺរ៉ុប និងអាហ្វ្រិក ដើម្បីកសាង«សហគមន៍វាសនារួម»។

«ឆ្នាំវប្បធម៌-ទេសចរណ៍ កម្ពុជា-ចិន» នាឆ្នាំ2019នេះ នឹងធ្វើអោយទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការ វប្បធម៌-ទេសចរណ៍ កម្ពុជា-ចិន កាន់តែរីកចម្រើន និងស៊ីជម្រៅ ថែមទៀតនាពេលអនាគតចាប់ពីពេលនេះ។

ជាទីបញ្ចប់ និងឆ្លៀតឱកាសចូលឆ្នាំចិនថ្មី ប៉ុន្មានថ្ងៃទៀតនេះ ខ្ញុំសូមជូនពរ ឯកឧត្តម លោកជំទាវ លោក លោកស្រី ទាំងអស់ ដែលមានវត្តមាននៅទីនេះ សូមប្រកប សូមអោយមានសុខភាពល្អ និងទទួល បានជោគជ័យជំផេងថែមទៀត ក្នុងគ្រប់ភារៈកិច្ច ខ្ញុំសូមប្រកាសបើកទិវា "ឆ្នាំវប្បធម៌-ទេសចរណ៍ កម្ពុជា-ចិន" ក្នុងឆ្នាំ2019នេះ។

សូមអរគុណ